N° 1
R. le 13-12-52
Meareatwichey
B - 3
D - 24
N - 2930
INDOCHINE FRANÇAISE
RÉGIE
DÉPÔT LÉGAL



# មាភនិវជ័យ

(មាននិទានគ្រប់គាថា)

ភិក្ខុ សុវណ្ណបញ្ញោ

គុយ-សែន

វត្តបាកយណ៍ព្រះជីវ៍ ឃុំបាកយណ៍

ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

រៀបរៀង

ការផ្សាយរបស់

បណ្ណាគារប៊ុត-សាខ

លេខ៥០ផ្លូវព្រៃនគរ ក្រុងភ្នំពេញ

រក្សាសិទ្ធិ

ព.ស. ២៤៩៥ គ.ស. ១៩៥២

ARCHIVES NATIONALES
DÉPOT LÉGAL
B-126-1538
-24
23-16-42
952

# អារម្ភកថា

ពុទ្ធជយមង្គលគាថាក្នុងផ្ទៃសៀវភៅនេះ ខ្ញុំយល់ឃើញថាពុទ្ធបរិស័ទជាច្រើនរូបដែលចេះចាំស្ទាត់គាថស្វាធ្យាយដោយមាត់ទទេបានមែន តែជាពុទ្ធបរិស័ទខ្លះចេះដឹងតាំងបុគ្គលាធិដ្ឋាន, ខ្លះពុំទាន់ចេះដឹង, អាស្រ័យហេតុនេះបានជាខ្ញុំស្រាវជ្រាវរកក្នុងទីតាន ក្នុងសុត្តន្តបិដកខ្លះ ក្នុងវិសុទ្ធិ-មគ្គខ្លះ ក្នុងធម្មបទដ្ឋកថាខ្លះ យកមករួបរួមក្រងទុកជាបុគ្គលាធិដ្ឋានប្រកបនឹងគាថាទាំង ៨ នេះ, លុះខ្ញុំរៀបរៀងរួចហើយក៏ពឹងភិក្ខុព្រហ្ម-បញ្ញាសិរី ម៉ៅ-ឌឹម គ្រូបង្រៀនបឋមវិជ្ជានឹងភិក្ខុ ជោតបញ្ញោ គូ-គីម ទាំងពីរអង្គនេះឲ្យជួយសរសេរ, លោកក៏ជួយដោយសេចក្តីសោមនស្សឥតនឹកដល់ការនឿយហត់ឡើយ ៗ លុះបានសម្រេចកិច្ចនេះហើយខ្ញុំក៏យកទៅប្រគល់ឲ្យលោកគុយ-សូត្រ ក្រុមជំនុំប្រែព្រះត្រៃបិដក នៃពុទ្ធសាសន-បណ្ឌិត្យ សុំឲ្យជួយពិនិត្យកែ ព្រមទាំងឲ្យបោះពុម្ពផ្សាយ ៗ ដោយកំ-លាំងនៃការខំរៀបរៀងនឹងការសរសេរទាំងពីរផ្នែកនេះ សូមឲ្យបុព្វការីទាំងឡាយមានមាតាបិតាជាដើមផង យើងខ្ញុំព្រមទាំងសត្វលោកផង បានជួបប្រទះតែឥដ្ឋារម្មណ៍គ្រប់ប្រការ អស់កាលជានិរន្តរតរៀងទៅ ៗ

ថ្ងៃសុក្រ ១១ កើតខែស្រាពណ៍ ឆ្នាំរោងចត្វាស័ក ព.ស. ២៤៩៥

ត្រូវនឹងថ្ងៃទី ១ ខែសីហា ឆ្នាំ ១៩៥២

ភិក្ខុសុវណ្ណបញ្ញោ គ-សែន

## បណាមគាថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ
(ព្រមទាំងព្រះធម៌និងព្រះសង្ឃដោយសេចក្ដីគោរព) ។

## ពុទ្ធជយមង្គលគាថា

១ – ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ
គ្រីមេខលំ ឧទិតឃោរសសេនមារំ
ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទ្រលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និម្មិតដៃមួយពាន់ កាន់សស្ត្រាវុធនានា ។
ជិះគ្រីមេខលជាតិ កោញ្ចនាទខ្ទរពសុធា
ព្រមដោយមារសេនា ពន្លឹកលាន់គងសព្ទស៊ាន ។
ដោយធម្មពិធី ទានបារមីជាប្រធាន
ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។
ជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជ័យា ព្រះឈ្នះមារគ្រានោះហោង ។

## រឿងព្រះឈ្នះមារាធិរាជ

បុគ្គលាធិដ្ឋានក្នុងផ្លូវនៃគាថានេះ មានសេចក្ដីដំណាលថា កាលដែលព្រះអង្គមានព្រះជន្មាយុ ២៩ ឆ្នាំ ទ្រង់នឿយណាយក្នុងរាជសម្បត្តិ ព្រោះឃើញទេវទូតទាំង ៤ គឺ: មនុស្សចាស់ ១, មនុស្សឈឺ ១, មនុស្សស្លាប់១, ភេទអ្នកបួស ១ ព្រះអង្គមានព្រះទ័យជ្រះថ្លាចំពោះភេទអ្នកបួស ក៏ចេញទៅសាងអភិនេស្ក្រមន៍ក្នុងថ្ងៃព្រហស្បតិ៍ពេញបូណ៌មី ខែអាសាឍ ឆ្នាំថោះ នាកណ្ដាលអធ្រាត្រស្ងាត់ គង់លើសេះកណ្ឋកៈមានខ្លួនប្រវែង ១៨ ហត្ថ នាយឆន្នាមាត្យតោងកន្ទុយសេះតាមទៅជាមួយផង បានជួបនឹងទេវ-បុត្តមារចុះពីទេវលោកមកឃាត់ថា "នែសិទ្ធត្ថ! អ្នកកុំទៅឡើយ នៅតែ៧ថ្ងៃទៀតទេ សម្បត្តិស្ដេចចក្រនឹងកើតមានប្រាកដដល់អ្នក" ព្រះ-អង្គឆ្លើយតបថា "នែមារ! យើងមិនត្រូវការទេ ចូរចៀសចេញ" ហើយហោះផ្លោះកន្លងនគរ ៣គឺ: នគរកបិលព័ស្ដុ ១, សាវត្ថី ១, វេសាលី ១ អស់រយៈផ្លូវចម្ងាយ ៣០ យោជន៍; នាឆ្នេរស្ទឹងអនោមាត្រើយនាយ ព្រះអង្គក៏ដោះគ្រឿងអលង្ការព្រមទាំងសេះប្រគល់ឲ្យឆន្នាមាត្យ ក៏កាត់ព្រះកេសាដោយព្រះខាន់ទិព្វ ទ្រទ្រង់បរិក្ខារ ៨ គឺ: ស្បង់១, ចីពរ១, សង្ឃាដី១, បាត្រ ១, កាំបិតកោរ ១, បំពង់ម្ជុល ១, វត្ថពន្ធចង្កេះ១, ដម្រងទឹក ១ ដែលឃដិការមហាព្រហ្មយកមកថ្វាយ ; លុះបព្វជ្ជាហើយ

ក៏ស្វែងរកសន្តិវរបទគឺព្រះនិព្វានរកគុណជាតិដទៃក្រៃលែងជាងគ្មាន ក៏ចូលទៅរកអាឡារតាបសកាលាមគោត្រ ទើបពោលយ៉ាងនេះថាៈ "ម្នាលកាលាមគោត្រដ៏មានអាយុ យើងប្រាថ្នានឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម៌វិន័យនេះដែរ" អាឡារតាបសក៏ពោលថា ល្អហើយ អ្នកចូរនៅចុះៗ ព្រះអង្គបានសិក្សាធម៌នោះបានសម្រេចរូបឈាន ៤ ដោយឆាប់រហ័ស បានធ្វើឲ្យជាក់ច្បាស់នូវលទ្ធិអាឡារតាបសដោយប្រាជ្ញារបស់ព្រះអង្គ ហើយក៏ថយអំពីទីនោះ ចូលទៅកាន់សំណាក់ឧទកតាបសរាមបុត្ត ក៏បានសម្រេចអរូបឈាន៤ទៀត បណ្តាធម៌ទាំងពីរបំណែកនោះមិនទាន់ល្មមប្រពេញព្រះទ័យ ក៏ស្តេចយាងទៅកាន់ចារិកក្នុងដែនមគធៈតាមលំដាប់ លុះដល់នូវសេនានិគមក្នុងឧរុវេលប្រទេស ទ្រង់ទតឃើញភូមិភាគបំណែកផែនដីជាទីត្រេកអរ មានដងព្រៃជាទីនាំមកនូវសេចក្តីជ្រះថ្លា មានស្ទឹងមានទឹកហូរដ៏ត្រជាក់ មានកំពង់គួររីករាយ មានស្រុកសម្រាប់គោចរមិនជិតពេកមិនឆ្ងាយពេកជុំវិញផង ក៏តាំងព្យាយាមគឺធ្វើទុក្ករកិរិយាក្នុងទីនោះ មានការបិទខ្យល់ចេញចូលតាមមាត់ ច្រមុះ ត្រចៀក និងការបន្ថយអាហារបន្តិចម្តងៗ រហូតដល់ប៉ុនគ្រាប់សណ្តែកបាយ ស្គាំងស្គមពេកណាស់ ព្រះកាយដូចវល្លិ៍ឃ្លោកត្រូវកំដៅក៏ស្វិតយ៉ាងនោះដែរ ពេលនោះទ្រង់មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលដែលមានកាយស្គាំងស្គមក្រៃពេកយ៉ាង

នេះមិនឆ្ងាយនឹងរកផ្លូវជាទីត្រាស់ដឹងបានឡើយ បើដូច្នេះគួរតែអាត្មាអញបរិភោគអាហារជាទិ ឲ្យរាងកាយនឹងនាំឲ្យពេញលេញវិញ ។

សម័យនោះឯងមានភិក្ខុ ៥ រូប គឺ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ១, ព្រះ-វប្បត្ថេរ ១, ព្រះភទ្ទិយត្ថេរ ១, ព្រះមហានាមត្ថេរ ១, ព្រះអស្សជិត្ថេរ ១ តាមបំរើព្រះអង្គដោយគិតថា សមណគោតមនឹងត្រាស់ដឹងធម៌ណា មុខជានឹងប្រាប់ធម៌នោះដល់យើងទាំងឡាយមិនខានឡើយ, ព្រះថេរៈទាំងនោះឃើញព្រះអង្គសោយបិណ្ឌបាតធម្មតាវិញ ក៏បបួលគ្នាទៅនៅឯព្រៃឥសិប-តនមិគទាយវនទាំងអស់ លុះក្រោយបន្តិចមកទៀត ទ្រង់បានទទួលមធុបាយាសអំពីនាងសុជាតា ជាធីតានៃសេនកុដុម្ពិកនៅស្រុកសេនានិគមក្នុងឧរុវេលាប្រទេសនោះ ព្រះអង្គពូតជា ៤៩ ពំនូតប៉ុនៗគ្រាប់ផ្លែត្នោតទ្រង់សោយក្បែរឆ្នេរស្ទឹងនេរញ្ជរា សោយស្រេចហើយក៏បណ្តែតថាសមាសទៅក្នុងស្ទឹង ដោយអំណាចទ្រង់អធិដ្ឋាន ថាសមាសក៏អណ្តែតច្រាសទឹកទៅបាន ៨០ ហត្ថ ក៏លិចធ្លាក់ចុះទៅដល់ពិភពកាឡនាគ ទង្គិចនឹងថាសព្រះពុទ្ធ ៣ ព្រះអង្គ ហើយសៀតស៊កពីខាងក្រោមថាសទាំង ៣ នោះឯង ។

លុះដល់ថ្ងៃរសៀល ព្រះអង្គយាងសំដៅទៅដើមពោធិព្រឹក្ស បានទទួលស្មៅស្គាអំពីសោត្ថិយព្រាហ្មណ៍នាកណ្តាលផ្លូវទៅក្រាលក្រោមដើម

ពោធិព្រឹក្ស ដែលមានកំពស់ ៥០ ហត្ថ រតនបល្ល័ង្កផុសឡើងកំពស់ ១៤ ហត្ថដោយអំណាចនៃបារមីមហាបុរស ព្រះអង្គក៏ឡើងគង់លើរតនបល្ល័ង្ក ហើយអធិដ្ឋានថា: ស្បែក, សរសៃ, ឆ្អឹង, ឈាម របស់អញចូរក៏ស្ងួតទៅចុះ បើអញមិនបានត្រាស់ដឹងទេ អញមិនក្រោកចេញពីទីនេះឡើយ ។ លុះដល់ព្រះអាទិត្យជិតអស្តង្គតទៅ ស្រាប់តែទេវបុត្តមារព្រមទាំងពួកពលមានកំពស់ ១២ យោជន៍ទាំងឆ្វេង-ស្តាំខ្ចបគ្នា ឯខាងលើមានកំពស់ ៩ យោជន៍ មកផ្ចាញ់ដើម្បីនឹងដណ្តើមយករតនបល្ល័ង្កពីព្រះអង្គ ទេវបុត្តមារជិះលើដំរីមេខលមានកំពស់ ១៥០ យោជន៍ និម្មិតដៃ ១ពាន់កាន់គ្រឿងផ្សេងៗ ឯពួកពលក៏និម្មិតខ្លួនផ្សេង ៗ ដែរ ទេវបុត្តមារបានសំដែងឫទ្ធិ ៩ បែបគឺ: ខ្យល់ព្យុះធំ ១, ភ្លៀងធំ ១, ភ្លៀងថ្ម ១, ភ្លៀងគ្រឿងប្រហារ ១, ភ្លៀងរងើកភ្លើង ១, ភ្លៀងផេះក្តៅ ១, ភ្លៀងដីខ្សាច់ ១, ភ្លៀងភក់ ១, ងងឹតអ័ព្ទសព្វទិស ១, ប៉ុន្តែហេតុទាំង ៩ យ៉ាងនេះក៏ក្លាយទៅជាគ្រឿងបូជាព្រះអង្គវិញ ។

ព្រះអង្គឈ្នះក្រុងមារព្រមទាំងសេនាពលក្នុងពេលនោះ ដោយបារមី ៣០ គឺបារមី ១០, ឧបបារមី ១០, បរមត្ថបារមី ១០, មហាបរិច្ចាគ ៥ និងចរិយា ៣ ប្រការទៀត ។

ឯមារកាលបើចាញ់តេជះព្រះមហាបុរសដូច្នេះហើយ ក៏លើកហត្ថ ទាំង ១ ពាន់ដាក់លើសិរសានមស្ការថា “ នមោ តេ បុរិសាជញ្ញ ” ដូច្នេះជា ដើមក៏ហោះបាត់អំពីទីនោះហោង ៗ

( ត្រង់ព្រះអង្គផ្ចាញ់មារនេះឯងជាបុគ្គលាធិដ្ឋាននៃគាថាទី ១ )

២ – មារាតិរេកមភិយុជ្ឈិតសព្វរត្តិំ

ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ

ខន្តីសុទន្តវិធិនា ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទជិនទាយក: ផ្ចាញ់អាឡវកយក្សឃោរឃៅ
រឹងរូសមិនគាំងនៅ ក្នុងខន្តីគុណសត្យា ៗ
រហូតអស់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា
ក្រៃលែងក្រុងមារា ក្នុងបឋមសម្ពោធិ ៗ
ដោយព្រះពិធីញាណ ទ្រង់ទូន្មានដោយខន្តី
ញុំាងចិត្តអសុរី ឲ្យបង់ព្យុះបុះវិន្ទា ៗ
វិជយមង្គល បូមានដល់អ្នកពល់គ្នា
ដោយតេជះជយា ព្រះឈ្នះអាឡវកយក្សហោង ៗ

# រឿងព្រះឈ្មោះអាឡវកាយក្ស

ក្នុងផ្ទៃនៃគាថានេះ មានសេចក្ដីដំណាលថា ក្នុងវស្សាទី ១៦ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងលំនៅរបស់អាឡវកយក្សជិតក្រុងអាឡវី ។

ពេលនោះ ព្រះរាជាជាធំក្នុងដែនអាឡវី ចេញទៅក្រសាលក្នុងឧទ្យានទឹងប្រពាតម្រឹគ ហើយទ្រង់ដាក់ព្រះរាជអាជ្ញាថា «បើម្រឹគគេចរួចត្រង់មុខអ្នកណា អ្នកនោះត្រូវទទួលទោសជាទម្ងន់» គ្រានោះមានម្រឹគមួយភិតភ័យត្រឡេកឃើញចន្លោះត្រង់ព្រះភ័ក្ត្រព្រះរាជា ជាកន្លែងស្ងាត់ ក៏ស្ទុះចេញទៅតាមទីនោះ ព្រះរាជា ក៏តាមបាញ់បាន សារពន្ទាស់សាច់រែកត្រឡប់មកឈប់សម្រាកព្រះកាយក្រោមម្លប់ជ្រៃមួយដើមជាអាណាខេត្តរបស់យក្សដែលចាតុម្មហារាជទាំង ៤ ប្រគល់អំណាចឲ្យចាប់អ្នកដំណើរទឹងសត្វតូច-ធំស៊ីបានទាំងរស់ ឯអាឡវកយក្សក៏ស្ទុះមកចាប់ព្រះរាជាប្រុងនឹងបរិភោគ ព្រះរាជាក៏អង្វរថា នែយក្ស ! ចូរអ្នកលែងយើងចុះ យើងនឹងបញ្ជូនមនុស្សម្នាក់ ៗ ព្រមទាំងបាយមួយភាជន៍ទៀតដល់អ្នករាល់ថ្ងៃ យក្សព្រមតាមព្រះរាជាប្រាប់ដូច្នោះហើយ ទើបលែងព្រះរាជាក្នុងពេលនោះឯង ព្រះរាជាទៀតសោត កាលបើយាងទៅដល់ព្រះរាជវាំងហើយ ទើបត្រាស់ហៅបុរសជានាយគុកមកប្រាប់តាមរឿងរ៉ាវសព្វគ្រប់ទាំងអស់ នាយគុកក៏ចាត់ការតាំងឲ្យអ្នកទោសម្នាក់ ៗ កាន់បាយមួយភាជន៍ ៗ ទៅឲ្យយក្សរាល់ថ្ងៃមិនដែលខានឡើយ ។ លុះយូរបន្តិចទៅមនុស្សក្នុងគុកអស់រលីង

នាយគុកក៏ទៅក្រាបទូលព្រះរាជាតាមដំណើររឿងរ៉ាវ ព្រះរាជាត្រាស់បង្គាប់គណ្ណា ថាបើបុរសឲ្យចំណាយព្រះរាជទ្រព្យដល់មនុស្សណាដែលអាចបានកាន់កាប់ឆ្ពាយនឹងខ្លួនឯងនឹងប្រគល់ឲ្យយក្សស៊ី ។

កន្លងតែព្រះអង្គគ្មានខណៈណាមួយ បានផ្ញើផ្លោះឡើយ ទើបពួកមហាមាត្យប្រឹក្សាគ្នាថា គួរបញ្ជូនមនុស្សចាស់ជរាទៅឲ្យយក្សស៊ី ព្រោះពពួកមនុស្សទាំងនេះជិតស្លាប់ហើយដែរ តែព្រះរាជាមិនព្រមអនុញ្ញាតផ្ញើផ្លោះទេ ទើបពួកមហាមាត្យក្រាបទូលទៀតថា គួរបញ្ជូនទារកតូច ៗ ព្រោះពួកទារកទាំងអម្បាលនោះមិនទាន់ស្គាល់មាតា-បិតាបងប្អូនណាស់នៅឡើយ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពួកមហាមាត្យក្រាបទូលផ្ញើផ្លោះហើយ ក៏ត្រាស់ថា បើយ៉ាងនេះទើបគួរ ។

ឯពួកពេជ្ឈឃាតកាលបើព្រះរាជាទ្រង់យល់ព្រមហើយ ក៏ដើរចាប់ទារកតូច ៗ យកទៅឲ្យយក្សស៊ីអស់រយៈ ១២ឆ្នាំ លុះសម័យតមកទៀតរកចាប់ទារកតូច ៗ មិនបាន ទើបនាំគ្នាទៅក្រាបទូលព្រះរាជាថា រកចាប់ទារកមិនបានទេ ឃើញមាននៅតែរាជកុមារដែលជាព្រះរាជបុត្ររបស់ព្រះអគ្គមហេសីព្រះពេជ្រចិន្ដានោះប៉ុណ្ណោះ ព្រះរាជាត្រាស់ថា រាជកុមារនេះជាទីស្រឡាញ់ពេញចិត្តរបស់អញ យ៉ាងណាមិញ ពួកឯងដទៃក៏ពេញចិត្តចំពោះកូនចៅអញដែរ; បើផ្លោះចូរចាប់យកទៅចុះ ។

ក៏ក្នុងថ្ងៃនោះឯង ព្រះដ៏មានព្រះភាគប្រមើលមើលឧបនិស្ស័យធម៌របស់សត្វដោយទិព្វចក្ខុ ទ្រង់ឈ្វេងយល់ឃើញថា អាឡវកកុមារមានឧបនិស្ស័យដល់អនាគាមិផល ឯអាឡវកយក្ស មានឧបនិស្ស័យដល់សោតាបត្តិផល ចំណែកពពួកជនទាំង ៨ម៉ឺន ៤ពាន់ទៀតសោត ក៏នឹងបានសម្រេចមគ្គផលច្រើនផង ទើបព្រះអង្គយាងទៅកាន់ទីលំនៅអាឡវកយក្សតែមួយព្រះអង្គឯងចម្ងាយផ្លូវ ៣០ យោជន៍ ។

គាប់ជួនពេលនោះ អាឡវកយក្សទៅកាន់យក្ខសន្និបាតឯព្រៃហិមពាន្ត លុះដល់ត្រឡប់មកវិញព្រមទាំងពួកពល ក៏ធ្វើចម្បាំងផ្ចាញ់ព្រះអង្គដោយហេតុ ៩ យ៉ាងគឺ: ខ្យល់ព្យុះធំ ១, ភ្លៀងមានគ្រាប់ថ្មោស ៗ ១, ភ្លៀងដុំថ្ម ១, ភ្លៀងគ្រឿងប្រហារគឺអាវុធផ្សេង ៗ ១, ភ្លៀងរងើកភ្លើង ១, ភ្លៀងផេះក្តៅ ១, ភ្លៀងដីខ្សាច់ ១, ភ្លៀងភក់ ១, បណ្តាលឲ្យងងឹតសព្វទិស ១, នឹងហេតុឯទៀត ៗ ជាច្រើន តែថារបស់ទាំងអម្បាលនោះក៏ក្លាយមកជាគ្រឿងបូជាព្រះអង្គទាំងអស់ ហេតុខាងក្រោយបំផុតគឺបោលទុស្សាវុធ (ផ្ទត់ក្រាល) ដែលមានអានុភាពខ្លាំងអស្ចារ្យ ត្រឡប់ទៅជារបស់ឥតអានុភាពវិញ ទើបនឹកក្នុងចិត្តថា សមណៈនេះប្រហែលជាប្រកបដោយមេត្តាទេដឹង? បើដូច្នោះអញនឹងផ្ចាញ់ផ្ចាលលោកដោយមេត្តាវិញ ហើយក៏ដើរចូលសំដៅទៅកាន់សំណាក់ព្រះដ៏មានព្រះភាគទើបពោលដូច្នេះថា:»

នែសមណៈ! លោកចូរចេញទៅ ព្រះដ៏មានព្រះភាគត្រាស់តបថា ល្អហើយ ៗ ស្តេចក៏ចេញទៅ ។ អាឡវកយក្សពោលទៀតថា “នែសមណៈ លោកចូរមកវិញ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា: ប្រពៃហើយ ៗ ក៏ស្តេចយាងចូលមកវិញ ។ អាឡវកយក្សពោលទៀតថា „ នែសមណៈ លោកចូលមកវិញ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ប្រពៃហើយៗ ស្តេចយាងចូលមកវិញ ។ អាឡវកយក្សពោលបង្គាប់យ៉ាងនេះអស់វារៈ ៣ ដង; លុះដល់វារៈទី ៤ ព្រះដ៏មានព្រះភាគត្រាស់តបថា តថាគត មិនចេញទៅទេ បើអ្នកប្រាថ្នានឹងធ្វើអ្វីដល់តថាគតក៏ធ្វើតាមចិត្តចុះ ។ អាឡវកយក្សពោលថា ម្នាលសមណៈ! ខ្ញុំនឹងសួរប្រស្នាចំពោះលោក, បើលោកមិនដោះប្រស្នាខ្ញុំទេ ខ្ញុំនឹងវះហឫទ័យ ឬ នឹងចាប់ជើងគ្រវែងទៅក្នុងត្រើយខាងនាយនៃស្ទឹងគង្គា មិនខានឡើយ, ព្រះដ៏មានព្រះភាគត្រាស់ថា បើអ្នកមានប្រាថ្នានឹងសួរនូវប្រស្នាណា ចូរសួរនូវប្រស្នានោះចំពោះតថាគតក្នុងកាលឥឡូវនេះចុះ ។

អាឡវកយក្សពោលពាក្យជាគាថាសួរថា:

កឹសូធ វិត្តំ បុរិសស្ស សេដ្ឋំ
កឹសុ សុចិណ្ណំ សុខមាវហាតិ
កឹសុ ហវេ សាទុតរំ រសានំ
កថំ ជីវី ជីវិតមាហុ សេដ្ឋន្តិ ។

អ្វីហ្ន៎ជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោកនេះ? អ្វីហ្ន៎ដែលបុគ្គលសន្សំដោយប្រពៃ ហើយនាំសេចក្ដីសុខមកឲ្យ? របស់អ្វីដែលមានរសឆ្ងាញ់វិសេសជាងរសទាំងឡាយ? ពួកអ្នកប្រាជ្ញពោលថាបុគ្គលដែលរស់នៅដូចម្ដេច ឈ្មោះថារស់នៅដ៏ប្រសើរ?

ព្រះអង្គត្រាស់ថា

សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
សច្ចំ ហវេ សាធុតរំ រសានំ
បញ្ញាជីវី ជីវិតមាហុ សេដ្ឋំ ។

សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោកនេះ សុចរិតធម៌ដែលបុគ្គលសន្សំដោយប្រពៃ តែងនាំសេចក្ដីសុខមកឲ្យ ពាក្យពិតជារសឆ្ងាញ់វិសេសជាងរសទាំងឡាយ ពួកអ្នកប្រាជ្ញពោលថាបុគ្គលដែលរស់នៅដោយប្រាជ្ញា ឈ្មោះថារស់នៅដ៏ប្រសើរ ។ (ឯប្រស្នាដែលយក្សសួរចំពោះព្រះដ៏មានព្រះភាគនោះនៅមានច្រើនតទៅទៀត តែសូមដកយកតែមួយគាថាជាឧទាហរណ៍ប៉ុណ្ណោះ )

វេលាដែលព្រះដ៏មានព្រះភាគដោះប្រស្នាចប់ អរុណក៏រះ យក្សក៏ថ្វាយសព្វសាធុការ ពួករាជបុរសក៏នាំរាជកុមារទៅឲ្យយក្សក្នុងពេលដំណាល

គ្នាតែម្ដងមិនមុនមិនក្រោយឡើយ; តែថាយក្សក៏មិនបានស៊ីកុមារនោះដែរ ព្រោះខ្លួនបានដល់ភាពជាសោតាបន្នបុគ្គលហើយ ។

(រឿងអាឡវកយក្សប្រកាន់ទីព្រះអង្គនេះឯងជាបុគ្គលាធិដ្ឋាននៃគាថាទី ២)។

៣ - នាឡាគិរឹ គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញដំរីឈ្មោះនាឡា
គិរីវរគជា ដ៏ហានក្លាចុះប្រេងព្រៃ ។
សាហាវឆាវឆេះដៃក្រៃ ដូចភ្លើងព្រៃឆេះកំទេច
មុតដូចចក្រកុតពេជ្រ ខ្លាំងដូចកាំអសនី ។
ដោយព្រះពិធីស្រប់ ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី ញុំាងដំរីឲ្យប្រែះថ្វា ។
ជ័យមង្គល ចូរមានដល់អ្នកពលគ្នា
ដោយតេជះជយា ព្រះឈ្នះនាឡាគីរី ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ
លេខកត :

## រឿងព្រះអង្គឈ្នះនាឡាគិរី

ក្នុងផ្នែកគាថានេះ មានសេចក្ដីដំណាលថា កាលព្រះដ៏មានព្រះភាគគង់នៅក្នុងវេឡុវនារាមជិតក្រុងរាជគ្រឹះ ទេវទត្តមានចិត្តប្រទូស្តចំពោះព្រះដ៏មានព្រះភាគ ព្យាយាមដើម្បីនឹងសម្លាប់ព្រះអង្គ ដោយធ្វើនូវបាបកម្មផ្សេង ៗ គឺប្រមៀលថ្មនឹងប្រកបខ្មាន់ធ្នូទៅសម្លាប់ព្រះអង្គជាដើម; ក៏ក្នុងសម័យនោះឯង ក្នុងក្រុងរាជគ្រឹះមានដំរីមួយឈ្មោះនាឡាគិរី ជាសត្វសាហាវតែងសម្លាប់មនុស្ស; លំដាប់នោះទេវទត្តចូលទៅកាន់នគររាជគ្រឹះក៏ដើរហួសទៅដល់រោងដំរី ហើយបាននិយាយពាក្យនេះនឹងពួកអ្នករក្សាដំរីថា នែនាយ ! យើងនេះជាញាតិនឹងស្ដេច អាចតាំងអ្នកដែលនៅក្នុងដំណែងទាបឲ្យនៅក្នុងដំណែងដ៏ខ្ពស់ក៏បាន អាចបង្កើនភត្តនឹងដំឡើងបៀវត្សក៏បាន ម្នាលនាយ ! បើដូច្នោះព្រះសមណគោតមយាងមកកាន់ច្រកនេះពេលណា ចូរអ្នកលែងដំរីនាឡាគិរីនេះឲ្យដើរសំដៅ ទៅកាន់ច្រកនេះក្នុងពេលនោះកុំខាន ពួកអ្នករក្សាដំរីទាំងនោះទទួលស្ដាប់ពាក្យទេវទត្តថា ករុណាលោកម្ចាស់ គ្រាក្រោយមកបន្តិច ព្រះដ៏មានព្រះភាគទ្រង់ស្បង់នឹងបាត្រក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងរាជគ្រឹះជាមួយនឹងភិក្ខុសង្ឃជាច្រើនរូប លំដាប់នោះព្រះដ៏មានព្រះភាគ ស្ដេចយាងទៅកាន់ច្រកនោះមែនឯពួកអ្នករក្សាដំរីទាំងនោះបានឃើញព្រះដ៏មានព្រះភាគស្ដេចយាងទៅ

កាន់ព្រែកនោះហើយ ក៏លែងដំរីឲ្យដើរសំដៅទៅកាន់ព្រែកនោះដែរ ឯដំរីនាឡាគិរីបានឃើញព្រះដ៏មានព្រះភាគស្តេចយាងមកអំពីចម្ងាយលឹមៗ ក៏លើកប្រមោយសម្រឹងត្រចៀកទឹងកន្ទុយ ស្ទុះសំដៅទៅរកព្រះដ៏មានព្រះភាគ ; ពួកភិក្ខុទាំងនោះឃើញដំរីមកអំពីចម្ងាយដូច្នោះហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ដំរីនាឡាគិរីនេះជាសត្វកាចកាក្រក់ណាស់ សម្លាប់មនុស្សអស់ជាច្រើនហើយ ឥឡូវនេះវាដើរមកកាន់ព្រែកនេះដែរ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគស្តេចគេចចេញ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកចូរមកតាមតថាគតចុះ កុំខ្លាចអ្វីឡើយ អ្នកណាមួយព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមរបស់អ្នកនោះមិនមែនជាហេតុមិនមែនជាឱកាសនឹងគួរធ្វើបានឡើយ ម្នាលភិក្ខុទាំងឡាយ ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គ មិនដែលមានព្រះសម្ពុទ្ធអង្គណាមួយ បរិនិព្វានដោយសេចក្តីព្យាបាទរបស់អ្នកដទៃទេ ពួកភិក្ខុទាំងនោះក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះអស់វារៈ ៣ ដង ព្រះដ៏មានព្រះភាគក៏ទ្រង់ប្រកែកអស់វារៈ ៣ ដងដែរ ។

សម័យនោះឯង មនុស្សទាំងឡាយនាំគ្នារត់ឡើងកាន់ប្រាសាទខ្លះ កាន់ផ្ទះខ្លះ កាន់ទីដទៃៗទៀតខ្លះ ឲ្យតែផុតអំពីសេចក្តីអន្តភយ ; ក៏បណ្តាមនុស្សទាំងអម្បាលនោះមនុស្សពួកណាដែលមិនទាន់មានសទ្ធា មិនទាន់ជ្រះថ្លា

អប្បឥតប្រាជ្ញាក៏និយាយគ្នាថា សមណគោតមនេះមានរូបល្អណាស់ ប៉ុន្តែ មុខជាទឹងត្រូវជំងឺបៀតបៀនក្នុងពេលនេះមិនខាន បំណែកពួកមនុស្សដែល មានសទ្ធាជ្រះថ្លា ជាបណ្ឌិតមានប្រាជ្ញាឈ្លាសវៃនិយាយគ្នាថា មិនយូរប៉ុន្មាន ទេ មុខជាព្រះសម្ពុទ្ធជាម្ចាស់នឹងឆ្លើសផ្ដាមជាមួយនឹងជំងឺនេះគង់ទ្រាំទានមិន ខានៗ លំដាប់នោះព្រះដ៏មានព្រះភាគទ្រង់ផ្សាយមេត្តាចិត្តទៅកាន់ដំរី ឯដំរី នោះកាលបើមេត្តាចិត្តរបស់ព្រះដ៏មានព្រះភាគផ្សាយមកប៉ះពាល់ត្រូវហើយ ក៏ដាក់ប្រមោយចុះក្រោម ចូលទៅជិតព្រះដ៏មានព្រះភាគបានឈរនៅ ចំពោះព្រះភក្ត្ររបស់ព្រះអង្គក្នុងពេលនោះឯង ៗ ទើបព្រះដ៏មានព្រះភាគ លើកព្រះហស្តខាងស្តាំស្ទាបពោងដំរីនាឡាគិរី ហើយមានពុទ្ធតម្រាស់ថា:

មា កុម្ភារ ឆាតមាសោ

ទុក្ខំ ហិ កុម្ភារ ឆាតមាសោ ។

ន ហិ ឆាតមាតស្ស កុម្ភារ

សុគតិ ហោតិ ឥតោ បរំ យតោ ។

មា ច មនោ មា ច បមានោ

ន ហិ បមត្តា សុគតឹ វេន្តិ តេ ។

ត្វេព្វារ តថា ការិស្សសិ

យេន ត្វំ សុគតឹ គមិស្សតិ ។

ម្នាលកុញ្ជរ អ្នកកុំចូលមកប៉ុនប៉ងសម្លាប់ព្រះពុទ្ធនាគឡើយ ម្នាលកុញ្ជរ ព្រោះថាការចូលមកប៉ុនប៉ងសម្លាប់ព្រះពុទ្ធនាគ ជាហេតុឲ្យកើតទុក្ខ ៗ ម្នាលកុញ្ជរ កាលបើអ្នកសម្លាប់ព្រះពុទ្ធនាគហើយ អំពីជាតិនេះទៅកាន់លោកខាងមុខ (អ្នក) មិនបានទៅកើតក្នុងសុគតិទេ ៗ ចូរអ្នកលែងស្រវឹង លែងប្រមាទទៅ ព្រោះថាសត្វទាំងឡាយដែលប្រមាទ ហើយតែងមិនបានទៅកាន់សុគតិភូមិឡើយ ៗ អ្នកនឹងទៅកាន់សុគតិ ដោយប្រការដែលអ្នកធ្វើខ្លួនឯង ៗ

លំដាប់នោះ ដំរីនាឡាគិរីបាចល្អងធូលីដែលជាប់នឹងព្រះបាទព្រះដ៏មានព្រះភាគ ដោយប្រមោយយកមកពោយរាយលើក្បាលហើយបែរមុខចំព្រះដ៏មានព្រះភាគ អង្គុញជើងមុខទាំងពីរថយក្រោយដកថយទាល់តែលែងឃើញព្រះដ៏មានព្រះភាគ ៗ លំដាប់នោះដំរីនាឡាគិរីទៅកាន់ទីលំនៅរបស់ខ្លួនដូចដើមវិញ ព្រះដ៏មានព្រះភាគទូន្មានដំរីដោយប្រការដូច្នេះឯង សម័យនោះឯង មនុស្សទាំងឡាយតែងនាំគ្នាច្រៀង ដោយពាក្យជាគាថាដូច្នេះថា:

ទណ្ឌេនេកេ ទមយន្តិ
អង្កុសេហិ កសាហិ ច
អទណ្ឌេន អសត្ថេន
នាគោ ទន្តោ មហេសិនា ៗ

សេចក្តីថា ជនពួកមួយ តែងទូន្មាន (ដំរី) ដោយដំបងខ្លះ ដោយកង្វេរខ្លះ ដោយរំពាត់ខ្លះ (ចំណែក) ព្រះពុទ្ធដែលព្រះអង្គស្វែងរកទូរគុណដ៏ធំឥតមានដំបង ឥតមានសស្ត្រាអ្វីទេ តែអាចទូន្មានហត្ថិនាគបាន ៗ

មនុស្សទាំងឡាយពោលទោសតិះដៀលបន្តុះបង្អាប់ថា ទេវទត្តនេះជាមនុស្សអាក្រក់ ជាអ្នកឥតបុណ្យសោះ មិនសមបើនឹងព្យាយាមសម្លាប់ព្រះអង្គដែលមានឫទ្ធិច្រើន មានអានុភាពច្រើនយ៉ាងនេះឡើយ ៗ

ទេវទត្តក៏សាបសូន្យលាភសក្ការៈជាងមុនទៅទៀត ចំណែកខាងព្រះដ៏មានព្រះភាគក៏បរិបូណ៌ដោយលាភសក្ការៈជាភិយ្យោភាព យ៉ាងអស្ចារ្យវិសេសរកទីបំផុតគ្មាន ៗ

ឯរឿងទេវទត្តមិនបានអធិប្បាយឲ្យវែងតទៅទៀតទេ ព្រោះមិនមែនជាវត្ថុបំណងឡើយ ៗ

(រឿងដែលព្រះអង្គទូន្មានដំរី ដោយមេត្តាចិត្តនេះឯង ជាបុគ្គលាធិដ្ឋាននៃគាថាទី ៣) ៗ

៤ – ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវន្តិយោជនបថង្គុលិមាលវន្តំ
ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ៗ

ព្រះមុនិន្ទពិនលោកត្រៃ
មានព្រះទ័យធ្វើបាដិហារិយ៍
ផ្ចាញ់ចោរអង្គុលិមាល
មានកម្រង់គឺម្រាមដៃ ។
នៃមនុស្សដែលគាត់កាត់
មកពាក់ពាត់ជាមាល័យ
អង់អាចកំណាចក្រៃ
ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវរំពារគ្រវី
ដេញព្រះមុនីសាស្ដាចារ្យ
ចម្ងាយផ្លូវកន្ទារ
កណ្ដាលព្រៃបីយោជនា ។
រីដយមគ្គល
ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា
ព្រះឈ្មះអង្គុលិមាល ។

## រឿងព្រះអង្គឈ្មោះអង្គុលិមាល

ក្នុងនៃគាថានេះ មានសេចក្ដីដំណាលថា សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់សម្រេចឥរិយាបថក្នុងវត្តជេតវ័នរបស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។

សម័យនោះឯង ក្នុងដែនព្រះបាទបសេនទិកោសលមានចោរម្នាក់ឈ្មោះអង្គុលិមាល ជាមនុស្សកាចអាក្រក់ មានដៃប្រឡាក់សុទ្ធតែឈាមស្និទ្ធក្នុងការសម្លាប់សត្វមានជីវិតពន់ពេកណាស់ ៗ ចោរនោះតែងធ្វើស្រុកនិគម-ជនបទឲ្យវិនាសខ្ចាត់ខ្ចាយអន្តរាយហិនហោចអស់ ហើយសម្លាប់មនុស្សកាត់យកម្រាមដៃធ្វើជាកម្រងពាក់យ៉ាងនេះឯង ។

គ្រានោះព្រះដ៏មានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត, លុះធ្វើភត្តកិច្ចរួចស្រេចហើយ ស្តេចយាងសំដៅទៅត្រង់ទីដែលអង្គុលិមាលចោរនៅ, ពួកមនុស្សអ្នកឃ្វាលគោ-ក្របី-ដំរី-សេះ និងអ្នកភ្ជួររាស់ជាដើម បានឃើញព្រះដ៏មានព្រះភាគកំពុងយាងសំដៅទៅកាន់ព្រៃដែលចោរអង្គុលិមាលនៅផ្ទុះនោះហើយ ក៏ស្ទុះរត់ចូលទៅក្រាបបង្គំទូលថា បពិត្រព្រះអង្គ សូមស្តេចកុំយាងទៅត្រង់ទីនុះឡើយ ដ្បិតទីកន្លែងនោះមានចោរម្នាក់ឈ្មោះអង្គុលិមាល កាចអាក្រក់មានដៃប្រឡាក់ឈាមជានិច្ច ស្និទ្ធក្នុងការសម្លាប់ពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ក្នុងពេលមុន ៗ ទោះបីបុរស ១០ នាក់ក្តី, ២០ នាក់ក្តី, ៣០ នាក់ក្តី, ៤០ នាក់ក្តី, អង្គុលិមាលចោរសម្លាប់ទាំងអស់ឥតសល់ម្នាក់សោះឡើយ ហេតុនេះ សូមព្រះអង្គកុំយាងទៅកាន់ទីនោះ ក្រែងមានអន្តរាយ ។

កាលបើមនុស្សទាំងនោះក្រាបទូលយ៉ាងនេះហើយ ព្រះអង្គទ្រង់ស្ងៀមះហើយចេះតែយាងទៅ; ពួកមនុស្សទាំងអម្បាលនោះតាមឃាត់ព្រះអង្គអស់វារៈ ៣ ដង តែព្រះអង្គមិនព្រមតាមពាក្យសំដីមនុស្សទាំងនោះឡើយ ។

ចំណែកឯអង្គុលិមាលចោរឃើញព្រះអង្គយាងមកអំពីចម្ងាយហើយ ក៏ត្រិះរិះក្នុងចិត្តថា យី អើអស្ចារ្យណាស់ ! អើហ្ន៎ ចំឡែកណាស់ !

ព្រោះទីនេះសូម្បីបុរសប៉ុន្មាននាក់ក៏ដោយ បើដើរមកកាន់ទីនេះហើយ តែងដល់នូវសេចក្ដីវិនាសក្នុងកណ្ដាប់ដៃរបស់អញទាំងអស់គ្នាមិនខាន ចុះសមណៈនេះតែម្នាក់ឯងសោះ ហ៊ានដើរមកកាន់ទីនេះឥតកោតញញើតអ្វីសោះឡើយ អញនឹងសម្លាប់សមណៈនេះឲ្យក្ស័យជីវិតក្នុងទីនេះដោយពិត ៗ

គ្រានោះអង្គុលិមាលចោរ ចាប់ដាវនឹងខែលសៀតក្នុងនឹងបំពង់ព្រួញ ព្រមទាំងគ្រឿងសស្ត្រាវុធសព្វគ្រប់ហើយ ក៏ស្ទុះដេញព្រះអង្គដែលយាងមកកាន់ទីនោះ ព្រះអង្គសំដែងឫទ្ធិឲ្យអង្គុលិមាលចោររត់ដេញអស់ទំហឹង ហើយក៏នៅតែមិនទាន់ព្រះអង្គដែលស្ដេចយាងតាមដំណើរប្រក្រតី គ្រានោះអង្គុលិមាលចោរមានសេចក្ដីត្រិះរិះថា អស្ចារ្យពេកណាស់ មិនដែលមានយ៉ាងនេះទេ ព្រោះគ្រាកាលមុនៗមក អញស្ទុះដេញចាប់ដំរីកំពុងបោលក៏បាន សេះកំពុងផាយក៏បាន សត្វម្រឹគតូច-ធំបានទាំងអស់ ដោយហោចទៅសូម្បីរថកំពុងបរយ៉ាងលឿនក៏គង់ចាប់បានដែរ ចំឡែកតែម្ដងនេះហេតុអ្វីបានជាអញរត់ដេញពេញទំហឹងហើយ ក៏នៅតែមិនទាន់សមណៈនេះដែលដើរតាមប្រក្រតីដូច្នេះ ៗ

អង្គុលិមាលចោរឈប់ឈរស្ងៀមហើយស្រែកឃាត់ព្រះអង្គថា នែសមណៈ ចូរឈប់សិន នែសមណៈចូរឈប់សិន ៗ ព្រះអង្គត្រាស់តបថា នែអង្គុលិមាល តថាគតឈប់ហើយ ចូរអ្នកឯងឈប់ដែរទៅ ៗ

គ្រានោះអង្គុលិមាលចោរគិតថា ពួកសមណៈនេះជាសក្យបុត្រ ធ្លាប់និយាយតែពាក្យពិត ប្រព្រឹត្តតែពាក្យពិត ចំណែកតែសមណៈនេះកំពុងដើរទេ ម្ដេចឡើយក៏និយាយថា នែអង្គុលិមាល តថាគតឈប់ហើយ ចូរអ្នកឈប់ផងទៅ, បើដូច្នោះ អញត្រូវសួរសមណៈនេះមើល ។

លំដាប់នោះអង្គុលិមាលចោរ ក៏ពោលនឹងព្រះដ៏មានព្រះភាគដោយពាក្យជាគាថាដូច្នេះថា ។

គច្ឆំ វទេសិ សមណាដ្ឋិតោម្ហិ
មមញ្ច ព្រូសិ ឋិតមដ្ឋិតោសិ
បុច្ឆាមិ តំ សមណ ឯតមត្ថំ
កថំ ឋិតោ ត្វំ អហមដ្ឋិតោម្ហិ ។

នែសមណៈ! លោកកំពុងដើរសោះទេ! ត្រឡប់និយាយថា តថាគតឈប់ហើយ ថែមទាំងថាឲ្យអញដែលឈប់ហើយថា អ្នកឯងទេ មិនទាន់ឈប់ដូច្នេះវិញ, នែសមណៈ! អញសូមសួរដំណើរនុ៎ះនឹងលោក លោកដែលឈប់ហើយតើដូចម្ដេច ។

ព្រះអង្គតបថា

ឋិតោ អហំ អង្គុលិមាល សព្វទា

សព្វេសុ ភូតេសុ និធាយ ទណ្ឌំ

តុវញ្ច បាណេសុ អសញ្ញតោសិ

តស្មា ឋិតោហំ តុវមដ្ឋិតោសិ

នែអង្គុលិមាល! តថាគតដែលបាននឈ្មោះថាឈប់ហើយ (នោះ) ព្រោះដាក់ចុះនូវគ្រឿងវាយដំចំពោះពួកសត្វទាំងអស់សព្វ ៗ កាល ឯអ្នកឯងជាអ្នកមិនសង្រួមក្នុងពួកសត្វ ព្រោះហេតុនោះ តថាគតទើបឈ្មោះថាជាអ្នកឈប់ហើយ អ្នកឯងឈ្មោះថាជាអ្នកមិនទាន់ឈប់ ។

(ឯអង្គុលិមាលចោរ បានស្តាប់ពុទ្ធត្រាស់យ៉ាងនេះហើយក៏មានហិរិនិងឱត្តប្បៈកើតឡើងក្នុងសន្តានយ៉ាងខ្លាំងអស្ចារ្យ ទើបពោលពាក្យតបចំពោះព្រះដ៏មានព្រះភាគដូច្នេះទៀតថា

នែសមណៈ! លោកស្វែងរកនូវគុណដ៏ធំ ជាអ្នកដែលទេវតានិងមនុស្សតែងបូជា លោកមកកាន់មហាវ៉ន (ដើម្បីសង្គ្រោះ) ដល់ខ្ញុំអស់កាលយូរហើយ ខ្ញុំនខ្ញុំនឹងប្រព្រឹត្តតាមនឹងលះបង់នូវបាបចោលចេញ ព្រោះបានស្តាប់នូវគាថារបស់ព្រះអង្គដែលប្រកបដោយធម៌ (អង្គុលិមាលចោរ) ថាដូច្នេះ

ហើយក៏គ្រវែងដាវទឹងអាវុធចោលទៅក្នុងត្រពាំង ក្នុងជ្រោះ ក្នុងរណ្តៅ អង្គុលិមាលចោរក៏ថ្វាយបង្គំព្រះបាទានៃព្រះសុគត ហើយសូមផ្នួសទឹង ព្រះអង្គក្នុងទីនោះឯង ។

ក៏ធម្មតាព្រះពុទ្ធទាំងឡាយ តែងប្រកបដោយករុណាស្វែងរកនូវគុណដ៏ធំ ដែលជាគ្រូនៃមនុស្សលោកព្រមទាំងទេវលោក បានជាព្រះអង្គត្រាស់ហៅអង្គុលិមាលនោះថា អ្នកចូរមកជាភិក្ខុចុះដូច្នេះ ; ក្នុងគ្រានោះ ភិក្ខុភាវៈនោះឯងក៏កើតមានដល់អង្គុលិមាលចោរនោះ ។

គ្រានោះព្រះភគវន្តមុនីទ្រង់នាំយកអង្គុលិមាលភិក្ខុសំដៅទៅកាន់ក្រុងសាវត្ថីសម្រេចឥរិយាបថនៅក្នុងវត្តជេតពន គាប់ជួនសម័យនោះ ពួកមហាជនក្នុងបុរីរបស់ព្រះបាទបសេនទិកោសល ស្រែកហៅគឹកកងថា បពិត្រព្រះសម្មតិទេព ក្នុងដែនរបស់ព្រះអង្គមានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាចកាក្រក់រកំចាត់កំចាយស្រុក, និគម, ជនបទឲ្យវិនាសអន្តរាយអស់ ហើយក៏សម្លាប់មនុស្សកាត់យកម្រាមដៃធ្វើជាកម្រងពាក់ សូមព្រះអង្គយាងទៅកំចាត់ចោរនោះចេញ លំដាប់នោះព្រះបាទបសេនទិកោសល ស្ដេចចេញអំពីក្រុងសាវត្ថីដោយសេះចំនួន ៥០០ យាងទៅកាន់អាពមទាំងថ្ងៃ ត្រង់ចូលសំដៅទៅរកព្រះដ៏មានបុណ្យ ហើយក្រាបថ្វាយបង្គំដោយបញ្ចប្រតិស្ឋាន ទើបព្រះអង្គត្រាស់សួរថា បពិត្រមហារាជ ទ្រង់ជាមហាបពិត្រ

ទ្រង់ខ្ញាល់នឹងបច្ចាមិត្តណាមួយឬ? ព្រះរាជាក្រាបទូលថា ខ្ញុំព្រះអង្គមិនមានក្រោធនឹងបុគ្គលណាមួយទេ តែថាមានចោរមួយឈ្មោះអង្គុលិមាលជាមនុស្សកាចអាក្រក់ពេកណាស់វាប្លន់បំផ្លាញស្រុក និគមជនបទ សម្លាប់មនុស្សកាត់ម្រាមដៃធ្វើកម្រងពាក់នៅក្នុងដែនរបស់ខ្ញុំព្រះអង្គនេះ ។

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងទៅកំចាត់ចោរអង្គុលិមាលនោះក្នុងកាលឥឡូវនេះ ព្រះអង្គត្រាស់សួរថា បើមហារាជឃើញអង្គុលិមាលចោរនោះជាភិក្ខុបព្វជិតវិញតើនឹងធ្វើដូចម្តេច? ព្រះរាជាក្រាបទូលថា ខ្ញុំព្រះអង្គនឹងបវារណាដោយបច្ច័យ ៤ មិនខាន ។

ជួនជាសម័យនោះឯង អង្គុលិមាលក៏កំពុងអង្គុយជិតព្រះដ៏មានបុណ្យ ៗ ក៏លើកព្រះហស្តខាងស្តាំចង្អុលបង្ហាញថា នុះហ្ន៎អង្គុលិមាល ព្រះរាជាទ្រង់ទតឃើញហើយ មានសេចក្តីភិតភ័យតក់ស្លុតយ៉ាងខ្លាំង ទើបព្រះអង្គត្រាស់ថា សូមមហារាជកុំភ័យឡើយ គ្រានោះព្រះរាជាចូលទៅថ្វាយបង្គំអង្គុលិមាលត្ថេរបវារណាដោយបច្ច័យ ៤ ហើយក៏យាងត្រឡប់ទៅកាន់ព្រះរាជដំណាក់ពេលនោះឯង ឯព្រះអង្គុលិមាលត្ថេរបានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះដ៏មានព្រះភាគ បានសម្រេចជាព្រះអរហន្តមួយអង្គដូចគេឯងដែរ ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា
លេខកូដ : ..................
លេខបញ្ជី : ..................

រឿងពាក់អង្គុលិមាលត្ថេរនេះនៅមានសេចក្តីពិស្តារតទៅទៀត តែបាដកស្រង់យកចំពោះហេតុតែត្រង់ព្រះអង្គបានទៅផ្ចាញ់បំណោះទេ ដើម្បីជាបុគ្គលាធិដ្ឋាននៃគាថាទី ៤ ប៉ុណ្ណោះឯង ។

៥– កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា
ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ
សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រស្តពាក្យនាងចិញ្ចា
អាពើធ្វើផ្តួចជា ស្រីមានគភ៌ចាស់ចើសពោះ ។
យកឈើធ្វើជាកូន ព័ន្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី ។
រម្ងាប់ពាក្យបណ្តាល នាគណ្តាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី គិសប្ចំពាក្យសត្យា ។
ជ័យមង្គល ចូរមានដល់អ្នកពល់គ្នា
ដោយតេជះជ័យា ព្រះសាស្តាឈ្នះចិញ្ចា ។

## រឿងព្រះអង្គឈ្មោះឆាងចិញ្ចា

គន្លងនៃគាថានេះ សូមសំដែងសេចក្ដីឲ្យជាក់ច្បាស់ ពីដំណើរហេតុដែលព្រះអង្គទ្រង់ផ្ចាញ់នាងចិញ្ចាមាណវិកានោះ ដូចមានសេចក្ដីតទៅនេះ ៖

សេចក្ដីដំណាលថា គ្រាបឋមពោធិកាល ព្រះអរហំសម្ពុទ្ធព្រមទាំងពួកសាវកមានគុណល្បីល្បាញប្រាកដក្នុងលោក មានទេវតានិងមនុស្សជាច្រើនដែរថ្វាយបំពោះគុណរបស់ព្រះអង្គ ក៏នាំយកលាភនិងសក្ការៈទៅបូជាច្រើនលើសលុបគ្រាប់ពុំបានឡើយ ។

ឯបក្សពួកតិរ្ថិយមិនមានបុគ្គលណាមួយផ្ទះថ្វាសោះ ម្លោះហើយជាបុគ្គលមិនសូវសម្បូរដោយលាភសក្ការៈប៉ុន្មាន ហើយក៏ដើរស្រែកប្រកាសក្នុងទីផ្សេងៗ ថា នែអ្នក ខ្ញុំនេះក៏ជាព្រះពុទ្ធ សមណគោតមក៏ជាព្រះពុទ្ធដូចខ្ញុំដែរ អ្នកឲ្យទានដល់សមណគោតមមានផលច្រើនយ៉ាងណា បើអ្នកឲ្យដល់ខ្ញុំវិញក៏មានផលច្រើនយ៉ាងនោះដែរ ។

ឯពួកតិរ្ថិយ បើទុកជាខំប្រឹងដើរបញ្ចុះបញ្ចូលពួកមហាជនដូច្នោះ ហើយក៏នៅតែមិនបានលាភសក្ការៈដូចបំណងឡើយ ។

ទើបគិតគ្នាថា យើងនឹងឲ្យនាងបរិព្វាជិកា ឈ្មោះចិញ្ចាមាណវិកា ដែលជាស្រីមានរូបល្អឆើតបំផុតនេះ ឲ្យរកឧបាយណាមួយនឹងលើក

ទោសចំពោះសមណគោតម លុះគិតដូច្នោះហើយក៏ប្រាប់ថា ម្នាលប្អូនស្រី នាងមានរូបល្អពន់ពេក ហេតុនេះចូរនាងធ្វើមុខមាយាកលណាមួយឲ្យជាទោសកើតឡើងដល់សមណគោតមក្នុងពេលនេះកុំខាន ឯនាងចិញ្ចមាណវិកានោះ កាលបើពួកតិរ្ថិយបង្គាប់ដូច្នោះហើយក៏តាក់តែងស្អិតស្អាងរាងកាយកាន់នូវគ្រឿងសក្ការៈផ្សេងៗមានកួងផ្កាជាដើមដើរសំដៅទៅកាន់វត្តជេតពន តែថាមិនចូលទៅកាន់វត្តនោះទេ ដើរហួសទៅកាន់វត្តតិរ្ថិយដទៃវិញ ធ្វើឫកពាបែបនេះតែរាល់ៗថ្ងៃ ។

ចំណែកឯពួកពុទ្ធបរិស័ទ កាលបើស្តាប់ធម៌រួចហើយក៏ចេញមកអំពីវត្តជេតពន តែងបានឃើញអាកប្បកិរិយានាងចិញ្ចមាណវិកានេះដូច្នេះរាល់ៗថ្ងៃ លុះកន្លងយូរខែ.ថ្ងៃទៅទើបសួរថា នាងមានការទៅទីណាតែយ៉ាងនេះរាល់ថ្ងៃពុំដែលខាន នាងក៏ឆ្លើយតបវិញថា ខ្ញុំទៅនៅសំណាក់អាស្រ័យក្នុងវត្តជេតពនជាមួយនឹងសមណគោតមបរមគ្រូរបស់អ្នកតាំងឡាយជាយូរខែណាស់មកហើយ ពួកមនុស្សអន្ធពាលទាំងឡាយក៏មានសេចក្តីសង្ស័យ តាមសំដីរបស់នាងនោះជាច្រើនណាស់ លុះដល់សម័យថ្ងៃក្រោយមកទៀត នាងនោះក៏បង្គាប់ឲ្យគេវាយខ្នងដៃនឹងជើងឲ្យមានសរីរៈហើមដូចជាស្រីមានគភ៌ពិតៗ ហើយនាងយកកំណាត់ឈើមកចងនឹងពោះ រុំសំពត់ពីខាងក្រៅមើលទៅគួរឲ្យសន្និដ្ឋានថាជាស្រីមានគភ៌

ពិតប្រាកដមែន ៗ កាលណោះព្រះលោកុត្តមាចារ្យជាកំពូលនៃគ្រូកំពុង តែសំដែងធម៌ត្រង់កណ្ដាលបរិស័ទទាំងបួនក្នុងសាលាសម័យនាវត្តជេត-ពននោះ ស្រាប់តែនាងបរិព្វាជិកាឈ្មោះចិញ្ចមាណវិកានេះ ដើរចូលទៅកាន់ចំណោមបរិស័ទដែលកំពុងស្ដាប់ធម្មទេសនានោះ ហើយឈរនៅក្នុងទីចំពោះព្រះភក្ត្រព្រះអង្គទើបពោលថា នែសមណៈលោកគិតតែសំដែងធម៌ធ្វើព្រងើយ ដោយការតែមានសំឡេងដ៏ពីរោះ មានបបូរមាត់ទន់ បំពេញញញើញចិត្តស្និទ្ធត្រមលប៉ុណ្ណោះ មិនគិតដល់ខ្ញុំដែលមានគភ៌ចាស់គ្រប់ខែផងសោះ គួរណាសំតែរកផ្ទះសម្រាប់ប្រសូតិ ទីឲ្យខ្ញុំសម្រាប់រក្សាគភ៌ផ្សេង ៗ ឲ្យខ្ញុំព្រះអង្គសិន កិច្ចទាំងនេះ បើមិនធ្វើដោយព្រះអង្គឯងក៏គួរតែបង្គាប់បញ្ជាឧបដ្ឋាកណាមួយឲ្យធ្វើជំនួសក៏បាន ព្រោះជាកិច្ចអាយពិត ខណៈនោះព្រះបរមគ្រូជាម្ចាស់ ទ្រង់បញ្ឈប់ធម្មទេសនាហើយ មានពុទ្ធតម្រាស់តបវិញថា ម្នាលប្អូនស្រី សំដីដែលនាងពោលមកទាំងប៉ុន្មាននេះ ជាសំដីពិតឬមិនពិតនោះ នាងឯងនឹងតថាគតគង់តែនឹងដឹងការណ៍នោះក្នុងកាលឥឡូវនេះមិនខាន ៗ

ក្នុងខណៈនោះឯង ព្រះឥន្ទ្រាធិរាជក៏ពិនិត្យមើលដោយទិព្វចក្ខុ បានឃើញនាងចិញ្ចមាណវិកា កំពុងតែពោលបង្កាច់ព្រះដ៏មានព្រះភាគដោយ

ពាក្យមិនពិតយ៉ាងនេះហើយ ក៏ចុះមកជាមួយនឹងទេវបុត្រ ៤ អង្គទៀត ទេវ-បុត្រទាំងនោះនិម្មិតខ្លួនជាកណ្តុរតូចៗ ត្បូលចូលទៅកាត់ខ្សែបំណង ដែលនាងចងព្យួងចំពោះនោះទ្យដាច់ស្មើគ្នាតែម្តង មណ្ឌលឈើនោះឯងក៏ធ្លាក់ចុះមកលើខ្លួនដើងរបស់នាងបែកចេញឈាមដោយមួយរំពេច ឯពុទ្ធបរិស័ទកាលបើឃើញហេតុមិនពិតដូច្នោះហើយក៏ផ្អើលឡោឡាឡើង, ខ្លះក៏ជេរខ្លះក៏គាន់នូវគ្រឿងប្រហារ វាយសំពងយ៉ាងដំណំ ក៏ដល់នូវទុក្ខវេទនាស្ទើរតែនឹងស្លាប់ ឯនាងចិញ្ចមាណវិកានោះដើរទៅឆ្ងាយផុតអំពីវត្តជេតពនរបស់ព្រះអង្គហើយមហាប្រថពីក៏ស្រូបនាងទាំងរស់ នាងក៏ដល់នូវសេចក្តីស្លាប់ធ្លាក់ទៅកើតក្នុងមហានរកឈ្មោះអវិចីរងទុក្ខលំបាក ដោយអំណាចកម្មដែលនាងធ្វើនូវអំពើដ៏លាមកដែលនាងបានពោលបង្កាច់ព្រះអរហំសម្ពុទ្ធជាម្ចាស់ដោយពាក្យមិនពិត ដូចអធិប្បាយខាងលើនេះស្រាប់ ។

រឿងរ៉ាវដែលព្រះអង្គបានផ្ចាញ់នាងចិញ្ចមាណវិកានោះអធិប្បាយមកប៉ុណ្ណោះនេះ គ្រាន់តែជាបុគ្គលាធិដ្ឋាននៃគាថាទី ៥ ប៉ុណ្ណោះឯង ។

៦- សច្ចំ វិហាយ មតិសច្ចកវាទកេតុំ

វាទាភិរោបិតមនំ អតិអន្ធភូតំ

បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាងដោយបញ្ញា
ផ្ចាញ់សច្ចកៈជា និគ្រន្ថក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់បៃ
សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់ ។
បង្កើតមោហ៍ងងឹត ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កំចាត់បង់ ដោយប្រទីបគឺបញ្ញា ។
ជ័យមង្គល ចូរមានដល់អ្នកពល់គ្នា
ដោយតេជៈជយា ឈ្នះសច្ចកៈនិគ្រន្ថ ។

## រឿងព្រះអង្គឈ្នះសច្ចកៈនិគ្រន្ថ

មានសេចក្ដីដំណាលថា សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅក្នុងកូដាគារសាលា មហាវនប្រទេសទៀបក្រុងសាវត្ថី; សម័យនោះឯង និគន្ថនាដបុត្រ ឈ្មោះសច្ចកៈ តែងពោលពាក្យក្នុងកណ្ដាលបរិស័ទរបស់ខ្លួនថា បុគ្គលណាមួយក្នុងលោកនេះ ទោះជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ប្ដេជ្ញាខ្លួន

ថាជាព្រះអរហំសម្ពុទ្ធ កាលបើគេញុលើកនូវទោសដោយសំដីហើយមិន រំភើបញាប់ញ័រ ទាំងញើសក៏មិនហូរចេញអំពីក្លៀកនោះមិនដែលមានទេ ចាំបាច់និយាយទៅថ្វីដល់មនុស្សសាមញ្ញផងទាំងពួងនោះ សូម្បីបង្គោលឈើក៏គង់ញាប់ញ័រពុំខានឡើយ ៗ

លំដាប់នោះឯងព្រះអស្សជិតត្ថេរស្លៀកស្បង់ប្រដាប់នូវបាត្រនិង ចីវរ ក្នុងបុព្វណ្ហសម័យចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលី ឯសច្ចកៈនិគ្រន្ថ ក៏កំពុងដើរសម្រាកស្រួលដែរ បានឃើញព្រះអស្សជិតត្ថេរហើយក៏ចូលទៅ ជិតនិយាយរាក់ទាក់ ហើយឋិតនៅក្នុងទីដ៏សមគួរទើបសួរថា បពិត្រលោក ម្ចាស់ដ៏ចំរើន ព្រះសមណគោតមតែងទូន្មានសាវករបស់ខ្លួនដូចម្ដេចខ្លះ? ព្រះអស្សជិតឆ្លើយតបថា ម្នាលអគ្គិវេស្សនៈ ព្រះបរមសាស្ដាតែងទូន្មាន ពួកសាវកថា ម្នាលភិក្ខុទាំងឡាយ រូបជារបស់មិនទៀង វេទនាជារបស់ មិនទៀង សញ្ញាជារបស់មិនទៀង សង្ខារទាំងឡាយជារបស់មិនទៀង វិញ្ញាណជារបស់មិនទៀង ជាប្រក្រតីយ៉ាងនេះ សច្ចកៈនិគ្រន្ថពោល តបវិញថា ខ្ញុំនឹងគិតធ្វើដូចម្ដេចឲ្យបានជួបព្រះនឹងបានចរចាជាមួយនឹង សមណគោតមនោះ ដើម្បីនឹងជួយដោះបុស្រាបស្រង់លោកឲ្យផុតអំពី ទិដ្ឋិដ៏លាមកអាក្រក់នេះចេញបានហ្ន៎! ក៏ក្នុងសម័យនោះឯង សច្ចកៈនិគ្រន្ថ ដើរបបួលពួកស្ដេចលិច្ឆវី បានចំនួន៥០០រូបដើរសំដៅទៅកូដាគារសាលា

នាំព្រៃមហាវ័ននោះ លុះដល់ទីនោះហើយក៏សំដែងសេចក្ដីរីករាយ យ៉ាង ស្និទ្ធជាមួយនឹងព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ទើប ពោលពាក្យយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមកនេះ មាន ប្រាថ្នានឹងសួរប្រស្នាចំពោះព្រះអង្គ តើបានឬទេ? ព្រះអង្គត្រាស់ថា បើអ្នក ត្រូវការនឹងសួរឬសួរមកចុះ ទើបសច្ចកៈនិគ្រន្ថសួរថា បពិត្រព្រះអង្គដ៏ ចំរើន ព្រះអង្គទូន្មានប្រៀនប្រដៅដល់ពួកសាវកដូចម្ដេចខ្លះ? ម្នាល អគ្គិវេស្សនៈ តថាគតតែងទូន្មានថា រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ទាំងនេះជារបស់មិនទៀង មិនមែនជារបស់ខ្លួនជារបស់មិនស្ដាប់បង្គាប់ទាំង អស់យ៉ាងនេះឯង បពិត្រព្រះអង្គដ៏ចំរើន មិនមែនដូច្នោះទេ រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ទាំងអស់នេះសុទ្ធតែជារបស់ទៀងទាត់ ជា របស់មិនប្រែប្រួល ជារបស់ខ្លួនពិត ៗ ម្នាលអគ្គិវេស្សនៈ បើដូច្នោះ តថា គតនឹងសួរថា អ្នកសព្វថ្ងៃនេះមិននៅក្រោមអំណាច អាណាព្យាបាល របស់ភិស្សជនមានស្ដេចជាដើមទេឬ? គឺធ្វើការអ្វី ៗ តាមអំពើចិត្តឬ? ម្យ៉ាងវិញទៀត រូបរបស់អ្នកនេះមិនលុះក្នុងអំណាចនៃជរា. ព្យាធិ. និង មរណៈជាដើមទេឬ? កាលបើព្រះដ៏មានព្រះភាគសួរដេញដោល យ៉ាង នេះហើយ សច្ចកៈនិគ្រន្ថក៏មិនអាចដោះស្រាយប្រស្នានេះបាន ក៏មាន សេចក្ដីតៀនគន់ មានមុខសំយុងចុះ មិនហ៊ានងើបសោះឡើយ ទើប

ព្រះអង្គត្រាស់សួរយ៉ាងនេះអស់វារៈពីរលើកទៀត សូចកៈនិគ្រន្ថមិនបាន ឆ្លើយតបតេសោះឡើយ ព្រះអង្គត្រាស់ថាម្នាលអគ្គិវេស្សនៈ អ្នកណាមួយក្នុងលោកនេះបើតថាគតសួរអស់វារៈបីដងនៅតែមិនឆ្លើយទេ អ្នកនោះមុខជានឹងបែកក្បាលជា ៧ ភាគ ក្នុងទីនេះមិនខាន ។ សម័យនោះឯងមានយក្សមួយឈ្មោះ វជិរបាណិ (ព្រះឥន្ទ្រ) កាន់ដម្បងដែកដូចជាកែវវជីរ ដែលឆេះព្រោលរន្ទាលសន្ធោសន្ធៅមកឋិតនៅឰដ៏អាកាសបំពីលើក្បាលនៃសូចកៈនិគ្រន្ថ បំរុងនឹងសំពងក្បាលបំបែក ឯយក្សនោះទៀតសោតគ្មានអ្នកណាមើលឃើញទេ មានតែសូចកៈនិគ្រន្ថ នឹងព្រះដ៏មាន-ព្រះភាគទើបមើលឃើញ លុះសូចកៈនិគ្រន្ថឃើញយក្សដូច្នោះហើយក៏មានសេចក្ដីតក់ស្លុតភិតភ័យយ៉ាងខ្លាំង ទើបក្រាបទូលថា ខ្ញុំព្រះអង្គមានព្រះពុទ្ធព្រះធម៌នឹងព្រះសង្ឃជាទីពឹងទីរឭកស្មើដោយជីវិត បពិត្រព្រះអង្គដ៏ចំរើន រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ជារបស់មិនទៀង មិនមែនជារបស់ខ្លួន ជារបស់មិនស្ដាប់បង្គាប់ ជារបស់លុះក្នុងអំណាចនៃជរាព្យាធិមរណៈទាំងអស់ ។

គ្រានោះឯងមានលិច្ឆវីបុត្រម្នាក់ឈ្មោះទុម្មុខ ពោលថា បពិត្រព្រះអង្គដ៏ចំ-រើន ខ្ញុំព្រះអង្គសូមត្រៀសេចក្ដីឧបមាថា ដូចជាបុរសម្នាក់ចុះកាន់ស្រះបោក្ខរណី

ហើយចាប់បានក្ដាមមួយយកមកលើគោកកាប់ដៃ ជើងអស់លើង ក្ដាមនោះមិនអាចវារចុះទៅកាន់ស្រះបោក្ខរណីវិញបាន យ៉ាងណាមិញ ឯសច្ចកៈនិគ្រន្ថនេះដូចគ្នានឹងក្ដាមដែលព្រះដ៏មានព្រះភាគបានកាប់ដៃ - ជើង ពោលគឺសេចក្ដីចំរូងចំរះដែលប្រកបដោយទិដ្ឋិផ្សេង ៗ យ៉ាងនេះឯង ។ បើអស់ជើងដៃគឺទិដ្ឋិយល់ខុសដូច្នេះហើយ ជាបុគ្គលលែងចុះកាន់ស្រះ គឺមិច្ឆាទិដ្ឋិ យ៉ាងនោះដែរ ចំណែកឯសច្ចកៈនិគ្រន្ថកាលបើដោះប្រស្នារបស់ព្រះដ៏មានព្រះភាគរួចហើយជាបុគ្គលមានព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិតលែងជឿគ្រូដទៃដូចមុន ៗ ទៀតឡើយហើយក៏និមន្តព្រះដ៏មានព្រះភាគព្រមទាំងភិក្ខុសង្ឃ ឲ្យទទួលភត្តក្នុងទីលំនៅរបស់ខ្លួនដោយសេចក្ដីជ្រះថ្លា យ៉ាងនេះឯង ។

ឯបញ្ហាដែលសច្ចកៈនិគ្រន្ថដោះស្រាយនោះនៅមានសេចក្ដីល្អិតជ្រាលជ្រៅពេកណាស់ តែថាមិនបានដកស្រង់យកមកដាក់ក្នុងទីនេះទេ គ្រាន់តែលើករឿងមកឲ្យឃើញថាព្រះដ៏មានព្រះភាគ ទ្រង់ផ្ចាញ់សច្ចកៈនិគ្រន្ថដោយការកាប់បង់នូវទិដ្ឋិដ៏អាក្រក់របស់គាត់ដូចបានអធិប្បាយជាសេចក្ដីខ្លីប៉ុណ្ណោះ នេះជាបុគ្គលាធិដ្ឋាននៃគាថាទី ៦ ដោយសេចក្ដីខ្លីសង្ខេបតែប៉ុណ្ណោះឯង ។

៧- នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ទមាបយន្តោ
ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទទ្រង់ញាណ ញុំាងមោគ្គល្លានមានអំណាច
ឲ្យប្អូនជានាគរាជ ទៅទូន្មានព្រះភុជង្គ ។
ឈ្មោះនន្ទោបនន្ទ ចិត្តអោហង្សរឿងឫទ្ធិរង
ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឲ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ខុនប៉ុះចាញ់ព្រះជេដ្ឋា ។
វិជយមង្គល ចូរមានដល់អ្នកពលគ្នា
ដោយតេជះជយា ព្រះភគវ៉ាឈ្នះនាគហោង ។

## រឿងព្រះអង្គឈ្មោះនាគរាជ

ក្នុងគាថានេះ មានសេចក្ដីដំណាលថា:

សម័យមួយ អនាថបិណ្ឌិកគហបតី ស្ដាប់ធម្មទេសនាព្រះដ៏មានព្រះភាគរួចហើយ និមន្តព្រះដ៏មានព្រះភាគព្រមទាំងព្រះភិក្ខុសង្ឃ ឲ្យទទួលភត្តក្នុងលំនៅរបស់ខ្លួន; ក៏ក្នុងថ្ងៃនោះ ព្រះដ៏មានព្រះភាគទ្រង់ប្រមើល

មើលឧបនិស្ស័យសត្វលោក ឃើញនន្ទោបនន្ទនាគ មានឧបនិស្ស័យគួរ ដល់ត្រូវវេនេយ្យដោយត្រូវចកពិត តែថាស្តេចនាគនោះជាមិច្ឆាទិដ្ឋិ មិនជ្រះថ្លាក្នុងព្រះរតនត្រ័យទេ ទើបត្រាស់ហៅអានន្ទត្ថេរ ព្រមទាំងភិក្ខុ-សង្ឃដើម្បីទៅកាន់ទេវចារិក; ក៏ក្នុងថ្ងៃនោះ ពួកបរិស័ទនន្ទោបនន្ទនាគ បានចាត់ចែងនូវរបៀបផ្សេង ៗ នឹងបាំងស្វេតច្ឆត្រ ព្រមទាំងរាំច្រៀងប្រគំជាដើម ថ្វាយនន្ទោបនន្ទនាគជាម្ចាស់របស់ខ្លួន ឯនន្ទោបនន្ទនាគឃើញព្រះអង្គព្រមទាំងពួកសាវក ទៅកាន់ចារិកនៃទេវតាផ្លូវហោះហើយ ក៏មានសេចក្តីក្រោធកើតឡើងដោយគិតក្នុងចិត្តថា ពួកសមណៈត្រមោលទាំងនេះ ហោះរំលងលើក្បាលរបស់ខ្លួន ក៏និម្មិតខ្លួនយ៉ាងធំសម្បើមអស្ចារ្យ ទៅព័ន្ធព័ទ្ធភ្នំសិនេរុ ៧ ជុំ ហើយបើកនូវពពារ ដើម្បីនឹងបិទបាំងបាន-តាវត្តឹង្ស មិនឲ្យព្រះអង្គនឹងពួកសាវកឃើញសោះឡើយ ៗ គ្រានោះឯងរដ្ឋបាលត្ថេរ ក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះពួកខ្ញុំព្រះអង្គទាំងអស់មើលភ្នំសិនេរុមិនឃើញ ឋានតាវត្តឹង្សក៏មិនឃើញ វេជយន្តប្រាសាទក៏មិនឃើញដែរ មិនដឹងជាហេតុអ្វីបិទបាំងទេ ម្នាលរដ្ឋបាល ស្តេចនាគឈ្មោះនន្ទោបនន្ទខឹងចំពោះយើងទាំងឡាយ មកព័ទ្ធព័ន្ធភ្នំសិនេរុ បើកពពារបាំង ៗ គ្រានោះពួកសាវកជាច្រើនអង្គមាន ព្រះថេរៈឈ្មោះរដ្ឋបាល, ព្រះថេរៈឈ្មោះភទ្ទិយ, ព្រះថេរៈឈ្មោះរាហុល,

ជាដើម សូមអាសាខ្ញុំទៅទូន្មាននាគ តែថាព្រះដ៏មានព្រះភាគមិនទ្រង់
អនុញ្ញាតឡើយ ដរាបដល់ទ្រង់អនុញ្ញាតដល់ព្រះថេរៈឈ្មោះមោគ្គល្លាន
ដែលសូមក្រោយគេបង្អស់ ឯព្រះថេរៈឈ្មោះមោគ្គល្លាន និម្មិតខ្លួនជានាគធំ
លើសជាងនន្ទោបនន្ទនាគនោះទៅទៀត ព័ទ្ធព័ទ្ធនន្ទោបនន្ទនាគ ដោយ
ភេនចំនួន ១៤ ជុំ រួចគេផ្ទប់នឹងក្បាលនៃ នន្ទោបនន្ទនាគ បានបញ្ចេញ
ផ្សែងនឹងភ្លើង ព្រះថេរៈក៏បញ្ចេញផ្សែងនឹងភ្លើងទៅវិញដែរ នន្ទោបនន្ទនាគ
អត់ទ្រាំមិនបាន ទើបសួរព្រះថេរៈថា ម្នាលអ្នកដ៏ចំរើន អ្នកជាអ្វីហ្ន៎
ព្រះថេរៈប្រាប់ថា ខ្ញុំជាមោគ្គល្លាន បពិត្រលោកម្ចាស់ដ៏ចំរើន សូមលែង
ខ្ញុំទៅ ព្រះថេរៈលែងហើយ ក៏ចូលតាមប្រហោងត្រចៀកខាងស្ដាំ ចេញ
តាមប្រហោងត្រចៀកខាងឆ្វេង ហើយចូលតាមប្រហោងច្រមុះខាងស្ដាំ
ចេញតាមប្រហោងខាងឆ្វេងវិញ ហើយក៏ចូលតាមមាត់ ដើរចង្ក្រមក្នុង
ពោះឯណោះទៀត ស្ដេចនាគគិតថា ភិក្ខុនេះកាលចូលទៅ អញមិនបាន
ឃើញសោះ ដល់ពេលចេញមកវិញអញនឹងខាំកំទេចត្រង់ចន្លោះធ្មេញ
មិនខាន ពេលនោះព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមោគ្គល្លាន អ្នកចូរ
តាំងស្មារតីឲ្យរឹងប៉ឹង ព្បិតនាគនេះមានឫទ្ធិច្រើនណាស់ ព្រះថេរៈក៏និម្មិតខ្លួន
ជាស្ដេចគ្រុឌ ដេញនន្ទោបនន្ទនាគ ៗ មានសេចក្ដីតក់ស្លុតខ្លាចជាខ្លាំង ក៏ប៉ុះ

បាញ់សាទុក្ខភាពនៃព្រះថេរៈថ្វាយបង្គំដោយសេចក្តីគោរពហើយពោលថា ខ្ញុំព្រះករុណា សូមផល់លោកម្ចាស់ជាទីពឹងទីរលឹក ព្រះថេរៈក៏នាំស្តេចនាគមកកាន់សំណាក់ព្រះដ៏មានព្រះភាគ ។ ទ្រង់ទូន្មានដោយបការៈ ផ្សេង ៗ នាគក៏ជាសត្វមានទិដ្ឋិដ៏ត្រង់ល្អដោយធម្មទេសនារបស់ព្រះអង្គយ៉ាងនេះឯង ។

( រឿងរ៉ាវដែលព្រះអង្គបានផ្ចាញ់នន្ទោបនន្ទនាគនោះ ដូចសេចក្តីដែលបានលើកយកមកសំដែងយ៉ាងសង្ខេបនេះ ជាបុគ្គលាធិដ្ឋាននៃគាថាទី ៧ ប៉ុណ្ណោះឯង ) ។

៨– ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទព្រីនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សំគាល់ថាគាត្មា រុងរឿងដោយគុណបរិសុទ្ធ ។
ដែកាន់អាសិរពិស គឺចិត្តទ្រិស្តិដ៏មុះមុត
កាន់ទុសត្រូវសម្មត្ត មិនលើកណាកលះបង់ព្រាណា ។
ទ្រង់ឈ្នះហើយពិធី ផុសបរិសេសសព្រោត្ត

ផុំត្រូវគាប់សន្តាន    គឺព្រះញាណប្រោសទេសនា ។
ដែលមង្គល    បូរមានដល់អ្នកពល់គ្នា
ដោយគេផ.ផយា    ឈ្មោះព្រហ្មឥតមានហ្ន៑ ។

រឿងព្រះអង្គឈ្មោះពកៈព្រហ្ម

ក្នុងផ្ទៃនៃគាថានេះមានសេចក្ដីដំណាលថា សម័យមួយព្រះដ៏មានព្រះ-ភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ត្រាស់ប្រាប់ភិក្ខុទាំងឡាយថា កាលតថាគតនៅក្នុងសុភគវន ទៀបគល់សាលព្រឹក្សនៅដែនឧក្កដ្ឋានោះ តថាគតបានដឹងនូវសេចក្ដីត្រិះរិះក្នុងចិត្តរបស់ពកព្រហ្ម ដោយទិដ្ឋិយល់យ៉ាងនេះថា ស្ថានព្រហ្មនេះជារបស់ទៀង ជារបស់ស្ថិតស្ថេរ ជារបស់មាននៅគ្រប់កាល ជារបស់មិនឃ្លៀងឃ្លាត ព្រោះទីនេះ មិនមានចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើយ ការរលាស់ខ្លួនចេញចាកភពដទៃទៀត ឲ្យក្រៃលែងជាងស្ថានព្រហ្មនេះមិនមានឡើយ តថាគតដឹងដូច្នោះហើយ ក៏ទៅកាន់ព្រហ្មលោកដោយមួយរំពេច ឯពកព្រហ្មបានឃើញតថាគតអំពីចម្ងាយហើយ ក៏ពោលពាក្យយ៉ាងនេះថា បពិត្រព្រះអង្គអ្នកនិទុក្ខ សូមស្ដេចយាងចូលមក ការយាងមកនេះ ប្រពៃហើយ ល្អហើយ ថែមទាំងនិយាយសរសើរអំពីស្ថានព្រហ្មនោះ តាមគំនិតដែលយល់ខុសទៀតផង ឯតថាគតបានពោលថា អើហ្ន៎

ពកព្រហ្មអ្នកប្រកបដោយអវិជ្ជាហើយតើ ! បានជាអ្នកពោលយ៉ាងនេះៗ

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះមារមានចិត្តបាបចូលដែកព្រហ្ម ឈ្មោះបារិសជ្ជាមួយរូប ពោលពាក្យនឹងតថាគតថា ម្នាលភិក្ខុ កុំបណ្ដោញ កុំបៀតបៀនព្រហ្មនេះឡើយ ព្រោះព្រហ្មនេះជាមហាព្រហ្ម ជាបុគ្គលច្បង ឥតមានបុគ្គលដទៃគ្របសង្កត់បាន ជាអ្នកឃើញហេតុពិត ជាអ្នកចាត់ចែងសត្វលោកទាំងអស់ ម្នាលភិក្ខុទាំងឡាយ តថាគតពោលតបវិញថា ម្នាលមារមានចិត្តបាប អ្នកកុំមើលងាយថា ឥតមានអ្នកណាមួយស្គាល់អញដូច្នេះឡើយ ព្រហ្មឯណាក្ដី បរិស័ទរបស់ព្រហ្មឯណាក្ដី ព្រហ្មបា-រិសជ្ជាឯណាក្ដី សុទ្ធតែលុះក្នុងកណ្ដាប់ដៃនៃអ្នកទាំងអស់ តថាគតបានស្គាល់គតិនិងអានុភាពរបស់ពកព្រហ្មថែមទៀតផង តថាគតនេះមិនមែនជាបុគ្គលស្មើនឹងអ្នកទាំងឡាយទេ ពេលនោះពកព្រហ្មពោលថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ណ្ហើយចុះខ្ញុំនឹងបំបាត់ខ្លួនក្នុងទីនេះឲ្យផុតអំពីព្រះអង្គក្នុងកាលឥឡូវនេះដោយពិត, ម្នាលព្រហ្ម អើកបើអ្នកអាចបំបាត់ខ្លួនឲ្យបាត់អំពីតថាគតបាន ចូរបំបាត់ទៅចុះ ពកព្រហ្មក៏មិនអាចបំបាត់ខ្លួនអំពីព្រះភក្ត្ររបស់ព្រះអង្គបានឡើយ ទើបព្រះអង្គត្រាស់ថា តថាគតអាចនឹងបំបាត់ខ្លួនអំពីមុខអ្នកវិញបាន គ្រានោះឯងព្រះអង្គបាននិម្មិតនូវឥទ្ធាភិ-

សង្ខារមានសភាពដូច្នេះហើយព្រហ្មទឹងបរិស័ទព្រហ្មទឹងព្រហ្មបារិសជ្ជា ពួ
តែសម្ដេចព្រះអង្គដែលពោលយ៉ាងនេះថា :

ករេភយំ ភយំ ទិស្វា

ករញ្ញ វិភវេសិ នំ

ករំ ឆាកិវេឌី ភាញ្ញិ

ធន្និញ្ញ ន ទុចាទិយន្តិ ៗ

តថាគតឃើញភ័យក្នុងភពផង ឃើញនូវពួកសត្វដែលកំពុងស្វែងរកនូវ ភពនឹងពិភពផង ហើយមិនបានពោលសរសើរ គឺមិនស្វែងរកភពណា មួយ ទាំងមិនប្រកាន់នូវសេចក្ដីត្រេកអរក្នុងភពឡើយ ៗ ពួកព្រហ្ម ទាំងនោះក៏កើតសេចក្ដីអស្ចារ្យក្នុងចិត្តថា ហេតុនេះជាអស្ចារ្យចំឡែក-ណាស់ មិនដែលមានយ៉ាងនេះទេ ព្រះសមណគោតមពេញជា មានឫទ្ធិច្រើន មានអានុភាពច្រើនពិតប្រាកដ ក្នុងពេលមុន ៗ មិនដែល បានឃើញបុគ្គលណា មានអានុភាពនឹងឫទ្ធិជាអស្ចារ្យយ៉ាងនេះឡើយ ៗ ព្រះដ៏មានព្រះភាគទ្រង់បានណែនាំពួកព្រហ្មឲ្យតាំងនៅក្នុងទិដ្ឋិដ៏ល្អដោយ បការដូច្នេះឯង ៗ

ឯរឿងរ៉ាវដែលព្រះអង្គបានផ្ចាញ់ពួកព្រហ្ម ដោយការគាប់បង់នូវទិដ្ឋិ

ដែលពកព្រហ្មយល់ខុសនោះ នៅមានសេចក្ដីល្អិតតទៅទៀត តែថាដក
ស្រង់មកប៉ុណ្ណោះនេះ ជាបុគ្គលាធិដ្ឋាននៃគាថាទី ៨ ប៉ុណ្ណោះឯង ។

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា
យោ វាចនោ ទិនទិនេ សរតេ មតន្ទ្រី
ហិត្វាននេកវិវិធានិ ចុបទ្ទវានិ
មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ ។

យោ នរោ ជនឯណា កប្បញ្ញាប្រាសក្តិខ្ជិល
ឧស្សាហ៍សាទរទានសីល សូត្ររំឭកព្រះធម៌ថ្ងៃ ។
គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
រំសូត្រសព្វ ៗ ថ្ងៃ កើតមង្គលជានិរន្តរ៍ ។
សោ នរោ ជននោះ បានល្ដះពេកអាសន្ន
ឧបទ្រពអនេកលន់ មានប្រការផ្សេង ៗ ផង ។
ទីដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្ទង
លែងទុក្ខចាំងបួនកង ដោយពុទ្ធជ័យមង្គលនេះ ។

(ចប់)